ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ: ៤៣៣. សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១១

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សូមគោរពជូន**

## ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន

**កម្មវត្ថុ:** ការរៀបចំតាក់តែងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវមេត្តាជ្រាបថា រយៈកាលកន្លងមកទីស្តីការគណៈរដ្ឋមន្ត្រីបានពិនិត្យឃើញថា គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ដែលក្រសួងស្ថាប័នបានតាក់តែងនិងផ្សព្វផ្សាយហើយនោះ នៅពុំទាន់ឯកភាពស៊ីចង្វាក់គ្នាពីទម្រង់នៅឡើយ ។

ដើម្បីឲ្យឯកសារទាំងនេះមានការឯកភាពគ្នា ទីស្តីការគណៈរដ្ឋមន្ត្រីបានប្រជុំអន្តរក្រសួងពិភាក្សាបកស្រាយគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានារបស់ក្រសួង ស្ថាប័នដែលមានកន្លងមក ហើយបានរៀបចំឲ្យមានភាពរលូនជាមួយគ្នា ឯកភាពគ្នាលើចំណុចគោលដែលត្រូវតាក់តែង និងនិយមន័យនៃពាក្យពេជន៍សំខាន់ៗខ្លះ ដូចមានទម្រង់នៃប្រភេទឯកសារនីមួយៗជូនភ្ជាប់មកស្រាប់ ។

សូមឯកឧត្តម លោកជំទាវមេត្តាជ្រាប និងអនុវត្តតាមការគួរ ។

សូមឯកឧត្តម លោកជំទាវមេត្តាទទួលនូវសេចក្តីរាប់អានដ៏ស្មោះពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**ចម្លងជូន:**
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ

# គោលនយោបាយ

## ( POLICY )

១- សេចក្តីផ្តើម (INTRODUCTION)

២- ចក្ខុវិស័យ (VISION)

៣- គោលបំណងនិងគោលដៅ (GOALS and OBJECTIVES)

៤- យុទ្ធសាស្ត្រ (STRATEGIES)

៥- ផែនការសកម្មភាព (ACTION PLAN)

- ការបង្កើតយន្តការ (ORGANISATIONAL MECANISM)
- ការបង្កើតក្របខណ្ឌគតិយុត្ត (LEGAL FRAMEWORK)
- ការគាំទ្រហិរញ្ញវត្ថុ (FINANCIAL SUPPORT)
- ការបណ្តុះបណ្តាលធនធានមនុស្ស (CAPACITY BUILDING)
- ដំណើរការអនុវត្តគម្រោង (PROJECT IMPLEMENTATION)
- ។ល។ (etc.)

៦- ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ (MONITORING and EVALUATION)

៧- សេចក្តីសន្និដ្ឋាន (CONCLUSIONS)

៨- សទ្ទានុក្រមឬវាក្យសព្ទ (ប្រសិនបើមាន) (LEXICON or VOCABULARY (if any))

# ផែនការយុទ្ធសាស្ត្រ

## ( STRATEGIC PLAN )

១- សេចក្តីផ្តើម (INTRODUCTION or BACKGROUND)

២- ចក្ខុវិស័យ (VISION)

៣- បេសកកម្ម (MISSION)

៤- គោលបំណងនិងគោលដៅ (GOALS and OBJECTIVES)

៥- ក្របខណ្ឌយុទ្ធសាស្ត្រ (STRATEGY FRAMEWORK)

- ការវិភាគជាយុទ្ធសាស្ត្រ (STRATEGIC ANALYSIS)
- ទិសដៅជាយុទ្ធសាស្ត្រ (STRATEGIC OBJECTIVES)
- យុទ្ធសាស្ត្រ (STRATEGIES)

៦- សកម្មភាពការងារ (ACTIVITIES)

៧- ធនធានហិរញ្ញវត្ថុ (FINANCIAL RESOURCES)

៨- ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ (MONITORING and EVALUATION)

៩-សេចក្តីសន្និដ្ឋាន (CONCLUSIONS)

# ផែនការសកម្មភាព

## ( ACTION PLAN )

១- សារបាន (BACKGROUND)

១.១- គោលនយោបាយ (POLICY)

១.២- ស្ថានភាព (SITUATION)

១.៣- បញ្ហាអទិភាព (PRIORITIES ISSUES)

២- យុទ្ធសាស្ត្រ (STRATEGIES)

៣- ផែនការសកម្មភាព (ACTION PLAN)

៣.១- បរិយាយសង្ខេបអំពីវិសាលភាពផែនការ (SUMMARY SCOPE OF PLANNING)

៣.២- តារាងអនុវត្តការងារ (MATRIX)

៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់-លិខិតបទដ្ឋានគតិយុត្ត (LAW and REGULATION DRAFTING SCHEDULE)

៥- គំរោងចំណាយ (EXPENDITURE)

៦- ការតាមដានត្រួតពិនិត្យនិងវាយតំលៃ (MONITORING and EVALUATION)

៧- សេចក្តីសន្និដ្ឋាន (CONCLUSIONS)